# ការធានារ៉ាប់រងអគ្គិភ័យ




*រូបភាពអគ្គិភ័យឆេះលំនៅដ្ឋានប្រជាជនក្នុងខេត្តកំពង់ស្ពឺ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦*

គ្រោះអគ្គិភ័យសុទ្ធតែធ្វើឲ្យមនុស្សគ្រប់គ្នាមានការភ័យខ្លាច ហើយវាអាចកើតឡើងក្នុងពេលណាមួយ ប្រសិនបើមិនមានការប្រុងប្រយ័ត្ន។ គ្រោះអគ្គិភ័យអាចកើតឡើងបានគ្រប់ពេលវេលា ដោយគ្មាននរណាម្នាក់អាចដឹងមុនបានឡើយ។

បច្ចុប្បន្ននេះ មានករណីអគ្គិភ័យកើតឡើងជារឿយៗក្នុងប្រទេសកម្ពុជាយើង ពោលគឺមិនថា ទីក្រុងភ្នំពេញ ឬជនបទនោះទេ ហើយមូលហេតុភាគច្រើនបណ្តាលមកពីការឆ្លងចរន្តអគ្គិសនី ការដុតភ្លើងទៀនធូប ដោយខ្វះការប្រុងប្រយ័ត្ន និងមូលហេតុផ្សេងៗទៀតជាដើម។ ជាក់ស្តែងរបាយការណ៍គ្រោះថ្នាក់សង្គមក្នុងឆ្នាំ **២០១៥** របស់ក្រសួងមហាផ្ទៃកន្លងទៅនេះបានបញ្ជាក់ថា មានករណីអគ្គិភ័យនៅទូទាំងប្រទេសមានចំនួន **៥៩០លើក** ក្នុងនោះមានអ្នកស្លាប់ចំនួន**៣៥នាក់** អ្នករបួសចំនួន**២៨នាក់** ឆេះផ្ទះចំនួន**៥៩៥ខ្នង** ឆេះតូបចំនួន**៣១៧ខ្នង** និងមានការខូចខាតទ្រព្យសម្បត្តិមាសប្រាក់សន្ធឹកសន្ធាប់ និងអាយុជីវិតប្រជាពលរដ្ឋមួយចំនួន។

ច្បាស់ណាស់ សំនួរបីខាងក្រោមបង្ហាញថាអគ្គិភ័យបង្កឲ្យមានការលំបាកធ្ងន់ធ្ងរដែលអាចធ្វើឲ្យមានវិបត្តិហិរញ្ញវត្ថុចំពោះម្ចាស់គេហដ្ឋាន ឬគ្រឹះស្ថានអាជីវកម្មនានា÷

១. តើនឹងមានបញ្ហាប្រឈមអ្វីខ្លះបើសិនជាផ្ទះសម្បែង ទ្រព្យសម្បត្តិ ឬអាជីវកម្មលោកអ្នកត្រូវបានបំផ្លាញដោយគ្រោះអគ្គិភ័យ?

២. តើលោកអ្នកនឹងធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាចំពោះមុខ?

៣ . តើលោកអ្នកត្រូវរកថវិកាពីប្រភពណា ដើម្បីសាងសង់ផ្ទះឡើងវិញ?

ដើម្បីបំបាត់ក្តីបារម្ភទាំងនេះ ការការពារដោយធានារ៉ាប់រងអគ្គិភ័យគឺជាដំណោះស្រាយមួយដ៏សំខាន់ ។ កិច្ចសន្យាធានារ៉ាប់រងអគ្គិភ័យភាគច្រើន គ្របដណ្តប់លើការខូចខាតទាំងឡាយ ដែលបង្កឡើងដោយករណីដូចខាងក្រោម÷

- ការខូចខាតដោយអគ្គិភ័យ និងរន្ទះ
- ព្យុះសង្ឃរា គ្រោះរញ្ជួយផែនដី និង បន្ទុះភ្នំភ្លើង ដែលបណ្តាលឲ្យកើតមានអគ្គិភ័យ
- បណ្តាលមកពីការធ្លាក់យន្តហោះ
- ការផ្ទុះនានា
- ដោយយានយន្តរបស់ភាគីតតិយជន
- ការខូចខាតដែលបណ្តាលមកពីផ្សែង
- ចំហេះដែលកើតឡើងដោយឯកឯង និង អគ្គិភ័យដែលបង្កឡើងដោយចរន្តអគ្គិសនី។

តាមរយៈការរៀបរាប់ខាងលើនេះ ភាពខុសគ្នារវាងអ្នកដែលគ្មានធានារ៉ាប់រង និងអ្នកដែលមានធានារ៉ាប់រងអគ្គិភ័យមានដូចខាងក្រោមនេះ÷

| **អ្នកគ្មានធានារ៉ាប់រងអគ្គិភ័យ** | **អ្នកមានធានារ៉ាប់រងអគ្គិភ័យ** |
|---|---|
| - លំបាកក្នុងការរកថវិកាដើម្បីសាងសង់ផ្ទះឡើងវិញ | - មិនបារម្ភអំពីថវិកាសម្រាប់ការសាងសង់ |
| - បាត់បង់ចំណូល | - រក្សាចំណូលឲ្យមានលំនឹង |
| - រំខានដល់ការធ្វើអាជីវកម្ម | - អាជីវកម្មលោកអ្នកនៅតែបន្តទៅមុខ |
| - បង្អាក់ការសន្សំប្រាក់ | - មិនចាំបាច់យកប្រាក់សន្សំមកសាងសង់ផ្ទះ |
| - អាចប៉ះពាល់ដល់ផែនការអនាគតរបស់លោកអ្នក | - មិនប៉ះពាល់ដល់ផែនការអនាគតរបស់លោកអ្នក |
| - ប៉ះពាល់ដល់អារម្មណ៍ផ្លូវចិត្ត | - សេចក្តីសុខផ្លូវចិត្ត (Peace of mind) |
| - ជំពាក់បំណុលកាន់តែច្រើន | - មានគម្រោងការត្រឹមត្រូវសម្រាប់អនាគត។ |

សរុបសេចក្តីមក ការធានារ៉ាប់រងអគ្គិភ័យគឺជាដំណោះស្រាយមួយ ចំពោះការគ្រប់គ្រងហានិភ័យរបស់ប្រជាពលរដ្ឋ ពិសេសក្នុងបរិបថនៃការរីកចម្រើននៃប្រទេសកម្ពុជាយើង និងកំណើននៃអាគារ និងការសាងសង់លំនៅដ្ឋានថ្មីៗ។ ការទទួលបានការការពារដោយធានារ៉ាប់រងអគ្គិភ័យ នឹងផ្តល់ឲ្យយើងទាំងអស់គ្នានូវសេចក្តីសុខផ្លូវចិត្ត និងភាពជឿជាក់ក្នុងជីវភាពកាន់តែប្រសើរជាងមុន។

សម្រាប់ព័ត៌មានបន្ថែម សាធារណជនទាំងអស់អាចធ្វើការទំនាក់ទំនងមកកាន់សមាគមធានារ៉ាប់រងកម្ពុជាតាមរយៈទូរស័ព្ទលេខ ០៩២ ៧៧៨ ១១១ និងអាចតាមដានរកព័ត៌មានបន្ថែមក្នុងគេហទំព័ររបស់សមាគម

www.iac.org.kh និងបណ្តាញសង្គមហ្វេសប៊ុក www.facebook.com/iaccambodia ។ រាល់ការពិភាក្សា និងសាកសួរព័ត៌មានទាំងអស់ គឺមិនតម្រូវអោយមានការបង់កំរៃអ្វីទាំងអស់ ។ សូមអរគុណ !